# សមាជិកភាពនៃ GSNV

លោកអ្នកពុំចាំបាច់ចូលជាសមាជិក GSNV ដើម្បីឲ្យបានទទួលកិច្ចបំរើពីយើងនោះទេ ក៏ប៉ុន្តែការចូលជាសមាជិកភាពអនុញ្ញាតឲ្យលោកអ្នកមានសិទ្ធិទទួលយក:

- ព្រឹត្តិប័ត្រ GSNV - ដែលផ្តល់ពត៌មាន ផ្នែកសុខភាពយ៉ាងច្រើនអំពីព្រឹត្តិការណ៍កើតមាននៅពេលខាងមុខ ឱកាសទទួលយកប្រាក់ឧបត្ថម្ភ និងដំណឹងជាច្រើនទៀត។
- ជួលបន្ទប់ដែលមានគ្រឿងឧបករណ៍ (អាស្រ័យទៅលើភាពទំនេររបស់បុគ្គលិក) និងគ្រឿងបរិក្ខារសំរាប់សន្និសិទ និងកិច្ចប្រជុំ។
- ការបញ្ចុះថ្លៃចុះឈ្មោះសំរាប់សិក្ខាសាលា និងសន្និសិទរបស់ **GSNV**។
- មានលទ្ធភាពទទួលយកគំរោងប្រាក់ឧបត្ថម្ភតូចតាច
- មានលទ្ធភាពជ្រើសរើសឲ្យឈរឈ្មោះសំរាប់មុខងារក្នុងគណៈកម្មការ។

## តើខ្ញុំអាចចូលរួមដោយរបៀបណា?

លោកអ្នកគ្រាន់តែបំពេញពាក្យសុំចូលជាសមាជិកភាពដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកព្រមជាមួយនឹងសែកបង់ទៅឲ្យ **Victorian Clinical Genetics Services** តាមអាសយដ្ឋាន:

Genetic Support Network of Victoria
PO Box 1100
Parkville, Victoria 3052

តម្លៃគិតបញ្ចូលពន្ធ GST

យើងនៅក្បែរលោកអ្នក ដូចខុមព្យូធើររបស់លោកអ្នកដែរ
**www.gsnv.org.au**

ឬសរសេរសំបុត្រមកយើងតាមរយៈអ៊ីម៉េល;
**info@gsnv.org.au**

ឬទូរស័ព្ទមកយើងតាមលេខ
**(03) 8341 6315**
(មានផ្តល់កិច្ចបំរើទូរស័ព្ទឆ្លើយតបមកវិញសំរាប់ TTY និងទីជនបទ)

ឬផ្ញើទូរសារមកយើង
**(03) 8341 6390**

សូមមកជួបយើងនៅជាន់ទី១០
**10th Floor**
**The Royal Children's Hospital**
**Flemington Road**
**Parkville, Victoria 3052**

**Genetic Support Network of Victoria**

"សម្រួលក្នុងការផ្តល់បណ្តាញព័ត៌មាន ទ្រទ្រង់ និងគាំទ្រ ដែលផ្តល់សិទ្ធិអំណាចដល់ប្រជាជនដើម្បីទប់ទល់នឹងឧបសគ្គផ្នែកតំណពូជ"

សូមកុំបោះពង្រាយ

ERC 060746



# Genetic Support
## Network of Victoria

# បណ្ដាញទ្រទ្រង់តំណពូជវិចតូរីយ៉ា

Cambodian



## ព័ត៌មាន

ទោះថាលោកអ្នកចូលចិត្តនិយាយប្រាប់នរណាម្នាក់តាមទូរស័ព្ទ រកមើលវ៉ិបសាយ ឬអានការចុះផ្សាយចុងក្រោយបំផុតណាមួយរបស់យើងក្តី យើងអាចផ្តល់ពត៌មានដែលលោកអ្នកត្រូវការ ផ្តល់ជូនលោកអ្នកនូវព័ត៌មានត្រឹមត្រូវទាន់ពេល មុនពេលតាមរយៈបុគ្គលិកធ្វើការដែលចេះដឹងពិតប្រាកដ។

សូមសួរយើងអំពី...

- ព័ត៌មានទាក់ទងលំអិតសំរាប់ក្រុមទ្រទ្រង់
- ធនធានសហគមន៍
- លក្ខណៈរោគតំណពូជ
- ប្រធានបទថ្មីៗអំពីតំណពូជ
- ព័ត៌មាន និងធនធានសំរាប់ក្រុមទ្រទ្រង់
- រៀបចំបង្កើតក្រុមទ្រទ្រង់
- និងជាច្រើនទៀត!

GSNV អាចភ្ជាប់ទំនាក់ទំនងជាមួយក្រុមទ្រទ្រង់ ដែលមានរួចមកហើយ ដើម្បីសំរួលការផ្តោះប្តូរទៅវិញទៅមកនូវព័ត៌មាន និងគំនិត ថែមទាំងភ្ជាប់ទំនាក់ទំនងលោកអ្នកទៅនឹងគ្រួសារឯទៀតដែលចែករំលែកពីស្ថានភាពរបស់លោកអ្នក។

## ការគាំទ្រ

**GSNV** មានគោលបំណងផ្តល់នូវការបញ្ចេញមតិយ៉ាងខ្លាំងក្លាសំរាប់អស់អ្នកដែលមានការប៉ះទង្គិចដោយលក្ខណៈរោគតំណពូជ។ ការនេះត្រូវសម្រេចបានតាមរយៈការតំណាង និងផ្សព្វផ្សាយអំពីសិទ្ធិរបស់សមាជិកទៅដល់សមាគមន៍ទូទៅ រដ្ឋាភិបាលប្រចាំរដ្ឋ និងរដ្ឋាភិបាលសហព័ន្ធ ព្រមទាំងផ្តល់នូវទំនាក់ទំនងរវាងសមាជិក និងស្ថាប័នផ្តល់កិច្ចបំរើផ្នែកសុខភាពទាំងឡាយ។

## ការទ្រទ្រង់

យើងផ្តល់នូវចំណុចទាក់ទងប្រកបដោយរាក់ទាក់ យកចិត្តទុកដាក់ អាចទទួលបាន ហើយច្បាស់លាស់សំរាប់បុគ្គលផ្ទាល់ខ្លួន និងគ្រួសារដែលប៉ះទង្គិចដោយលក្ខណៈរោគតំណពូជ។

**GSNV** មានគោលបំណងផ្តល់ជូនប្រជាជននូវការទ្រទ្រង់សមរម្យ និងទាន់ពេល ព្រមទាំងជួយទៅដល់ក្រុមទ្រទ្រង់ផងដែរ។ យើងមានមោទនភាពដើម្បីជួយក្នុងការបង្កើតឲ្យមានក្រុមទ្រទ្រង់ថ្មីៗ ហើយអាចជួយផ្តល់នូវព័ត៌មានផ្នែកចាត់ចែង ថវិការ និងការបង្កើតសាជីវកម្ម។

## ការអប់រំ

**GSNV** មានគោលបំណងទ្រទ្រង់សមាជិករបស់ខ្លួន ដោយផ្តល់នូវបទពិសោធន៍ផ្នែកអប់រំដូចជាការពិភាក្សាយោបល់ជាក្រុម និងសិក្ខាសាលាដើម្បីជួយសមាជិកទាំងនោះបង្កើននូវចំណេះដឹង និងផ្នែកជំនាញ – ចាប់ពីការពិភាក្សាយោបល់ជាក្រុមស្តីអំពីការដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ ទៅដល់សិក្ខាសាលាអំពីលក្ខណៈរោគជាក់លាក់ ឬអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រ។ **GSNV** ក៏ផ្តល់ផងដែរនូវឱកាសឲ្យសមាជិកចូលរួមនៅក្នុងព្រឹត្តិការណ៍ទាំងឡាយ ដើម្បីអប់រំសហគមន៍ទូទៅអំពីបញ្ហាទាក់ទិននឹងឧបសគ្គផ្នែកតំណពូជ។

សូមសួរយើងអំពី...

- សិក្ខាសាលាដែលនឹងមានក្នុងពេលខាងមុខ
- សប្តាហ៍សម្រាប់ការយល់ដឹងអំពីការទ្រទ្រង់ផ្នែកតំណពូជ



# ពាក្យសុំចូលជាសមាជិកភាព

ងារ (សូមគូសយកជារង្វង់មូល)　លោក　លោកស្រី　អ្នកស្រី　កញ្ញា　បណ្ឌិត

នាមខ្លួន

នាមត្រកូល

ឈ្មោះអង្គការ (ប្រសិនបើទាក់ទិន)

អាសយដ្ឋាន

រដ្ឋ　　លេខតំបន់

ទូរស័ព្ទ (កន្លែងធ្វើការ)　　ទូរស័ព្ទ (ផ្ទះ)

ទូរស័ព្ទចល័ត　　ទូរសារ

អ៊ីម៉េល

ប្រភេទសមាជិកភាព: (សូមមើលខាងក្រោម)

1. គ្រួសារ/បុគ្គល　$22 ☐
2. ជាក្រុម　$22 ☐
3. អាជីព/ស្ថាប័នផ្តល់កិច្ចបំរើ　$22 ☐
4. សម្បទាន (ការចុះថ្លៃ)　$11 ☐

(សិស្ស អ្នកទទួលប្រាក់សោធន អ្នកកាន់ប័ណ្ណមើលថែសុខភាព)

ដាក់បញ្ចូលតែក្នុងបញ្ជីផ្ញើប៉ុណ្ណោះ　មិនអនុវត្តទេ ☐

ហត្ថលេខា

ថ្ងៃទី　/　/

តើលោកអ្នកបានដឹងឮអំពីយើងដោយរបៀបណា?